ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០៥នាក់ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **ចំនួនអ្នកព្យាបាលជាសះស្បើយ** សរុបទូទាំងប្រទេស មានចំនួន **១៣៣នាក់** (ស្មើនឹង ៧៧,៧៨% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងបុរស ៩៤នាក់
- **អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ** មានចំនួន ៣៦នាក់ ៖
  - បុរសជនជាតិខ្មែរ ០៧ នាក់ និងស្ត្រីជនជាតិខ្មែរ ០១នាក់ ដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ីកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
  - បុរសជនជាតិខ្មែរ ២៥នាក់ ដែលបានវិលត្រឡប់មកពីប្រទេសអារ៉ាប់ប៊ីសាអូឌីត និងបុរសជនជាតិខ្មែរ ០២នាក់ និងស្ត្រី ០១នាក់ ដែលបានវិលត្រឡប់មកពីសហរដ្ឋអាមេរិក (ជាករណីខាងក្រោមនេះ) កំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ
- **អ្នកសម្រាកព្យាបាលនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា៖** ជនជាតិអាមេរិក ០២នាក់
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** នៅទូទាំងប្រទេស សរុបចំនួន **១៧១នាក់** (ស្ត្រី ៤២នាក់ និងបុរស ១២៩នាក់)។

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី** ចំនួន **០៥នាក់** (បុរសជនជាតិខ្មែរចំនួន ០២នាក់ ស្ត្រីជនជាតិខ្មែរ ០១នាក់ និងបុរសជនជាតិអាមេរិកចំនួន ០២នាក់) នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**២.១. ករណីជនជាតិខ្មែរ ០៣នាក់ វិជ្ជមានវីរុសកូវីដ-១៩** (លទ្ធផលទទួលបានពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា) ៖

- បុរសអាយុ ៣៨ឆ្នាំ និងកូនប្រុសបង្កើតអាយុ ៥ឆ្នាំ មានអាស័យដ្ឋាននៅចាក់អង្រែក្រោម រាជធានីភ្នំពេញ ដែលបានទៅលេងឪពុកម្តាយនៅសហរដ្ឋអាមេរិក តាំងពីខែមីនា ឆ្នាំ២០២០ ជាមួយភរិយា និងកូនស្រីម្នាក់ទៀត (តែស្ត្រីទាំងពីរនាក់ មានលទ្ធផលតេស្តលើកទី១នេះ អវិជ្ជមានកូវីដ-១៩)


ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥ ២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- ស្ត្រីអាយុ ៦០ឆ្នាំ រស់នៅសហរដ្ឋអាមេរិក ដែលមានអាស័យដ្ឋានស្នាក់នៅក្នុងបុរីប៉េងហួតបឹងស្នោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានរោគសញ្ញាហៀរសំបោរ (ស្រដៀងផ្តាសាយ) តាំងពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០២០។

**សម្គាល់៖** បុគ្គលទាំងបីនាក់ខាងលើ បានធ្វើដំណើរមកពីសហរដ្ឋអាមេរិក បន្តជើងហោះហើរលេខ BR265 នៅប្រទេសចិន (តៃប៉ិ) មកដល់ប្រទេសកម្ពុជាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។ លទ្ធផលវិភាគវត្ថុសំណាករបស់ពួកគាត់ទាំងបីនាក់ ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ហើយបច្ចុប្បន្ន ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ។ តាមជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ៧៧នាក់ (ស្ត្រី ២៦នាក់ ក្មេងតូច ០២នាក់ កុមារ ៨នាក់ និងបុរស ៤០នាក់) ដែលក្នុងចំនួនសរុបនេះ មានជនជាតិចិន (តៃវ៉ាន់) ៣៦នាក់ ជនជាតិជប៉ុន ០១នាក់ និងជនជាតិអាមេរិកកាំង ១៩នាក់។ អ្នកដំណើរដែលមានលទ្ធផលតេស្តអវិជ្ជមានកូវីដ-១៩ទាំងអស់ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដើម្បីតាមដានសុខភាពបន្ត ដោយចែកចេញជា៖ ចំនួន ០៨នាក់នៅមណ្ឌលចត្តាឡីស័កទ័ពអាកាស រាជធានីភ្នំពេញ និងចំនួន ៦៦នាក់ នៅសណ្ឋាគារអូខេប៉ាឡេស រាជធានីភ្នំពេញ ។

**២.២. ករណីជនជាតិអាមេរិក ០២នាក់ វិជ្ជមានវីរុសកូវីដ-១៩** (លទ្ធផលទទួលបានពីស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា) ៖

- ជនជាតិអាមេរិកពីរនាក់ (អាយុទាំងពីរនាក់ មិនបានរាយការណ៍ពីស្ថានទូតអាមេរិកនៅកម្ពុជាមកទេ) ជាមន្ត្រីការទូតជាន់ខ្ពស់សហរដ្ឋអាមេរិកកកាន់វីសាប្រភេទ A មានអាស័យដ្ឋានស្នាក់នៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា រាជធានីភ្នំពេញ។

**សម្គាល់៖** ជនជាតិអាមេរិកកាំងទាំងពីរនាក់ខាងលើ បានធ្វើដំណើរពីសហរដ្ឋអាមេរិក បន្តជើងហោះហើរលេខ KE689 នៅកូរ៉េខាងត្បូង មកដល់ប្រទេសកម្ពុជាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។ លទ្ធផលវិភាគវត្ថុសំណាករបស់ពួកគាត់ ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ អ្នកជំងឺទាំងពីរនាក់ ស្ថិតនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិក រាជធានីភ្នំពេញ។

សូមកត់សម្គាល់ផងដែរថា តាមជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ៩១នាក់ (ស្ត្រី ៣២នាក់ កុមារ ០៧នាក់ និងបុរស ៥២នាក់) ដែលក្នុងចំនួនសរុបនេះ មានជនជាតិកូរ៉េ ២៨នាក់ ជនជាតិអាមេរិក ១៩នាក់ (កុមារ ០២នាក់) ជនជាតិបារាំង ០២នាក់ ជនជាតិវៀតណាម ០២នាក់ ជនជាតិអូស្ត្រាលី ០៤នាក់ (កុមារ ០២នាក់) ជនជាតិឥណ្ឌូណេស៊ី ០១នាក់ ជនជាតិញូវែលហ្ស៊ីឡង់ ០៣នាក់ (កុមារ ០១នាក់) ជនជាតិចិន ០៣នាក់ ជនជាតិអូទ្រីស ០១នាក់ ជនជាតិ អង់គ្លេស ០៤នាក់ (កុមារ ០២នាក់) ជនជាតិហ្វាំងឡង់ ០១នាក់ និងជនជាតិកាណាដា ០១នាក់។

អ្នកដំណើរទាំងអស់ដែលបន្តជើងហោះហើរតាមចិន (តៃប៉ិ) ខាងលើនេះ មានអ្នកធ្វើដំណើរដែលបានចេញមកពីប្រទេសខុសៗគ្នា គឺមាន៖ ចេញដំណើរមកពីប្រទេសកូរ៉េ (៤២នាក់) ប្រទេសអាមេរិក ១៧នាក់ (កុមារ ០២នាក់) ប្រទេសកាតា ០២នាក់ ប្រទេសសាំងហ្គាពួរ ០៤នាក់ (កុមារ ០២នាក់) ប្រទេសឥណ្ឌូណេស៊ី ០១នាក់ ប្រទេសញូវែលហ្ស៊ីឡង់ ០៣នាក់ (កុមារ ០១នាក់) ប្រទេសចិន (ហុងកុង) ០៣នាក់ ប្រទេសម៉ុងហ្គោលី ០១នាក់ ប្រទេសហូឡង់ ០៤នាក់ (កុមារ ០២នាក់) និងចេញពីប្រទេសកាណាដា ០៤នាក់។

អ្នកដំណើរដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ទាំងអស់ ត្រូវបានដាក់ឲ្យនៅធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដើម្បីតាមដានសុខភាពបន្ត ដោយចែកចេញជា ៖ នៅមណ្ឌលចត្តាឡីស័កទ័ពអាកាស រាជធានីភ្នំពេញ ចំនួន ១០នាក់ និងចំនួន ៧៩នាក់ទៀត ត្រូវបានដាក់ឲ្យស្នាក់នៅសណ្ឋាគារមួយ ក្នុងសង្កាត់បឹងកេងកងមួយ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០